ធ្វើនៅភ្នំពេញ , ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៣

# សេចក្តីសំរេច លេខ ២២ សសរ

## ស្តីពីការបង្កើតគណៈកម្មការពិគ្រោះការងារ ដើម្បីពង្រីកកិច្ច សហប្រតិបត្តិការរវាងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដើម្បីរៀបចំកងកំលាំង ប្រដាប់អាវុធកម្ពុជា

* * *

### រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ សម្តេចព្រះប្រមុខរដ្ឋ ចុះថ្ងៃទី ០២ ខែ កក្កដាឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា
- យោងតាមកិច្ចព្រមព្រៀងរវាង រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋបារាំង អំពីកិច្ចសហប្រតិបត្តិការ បច្ចេកទេស ក្នុងវិស័យការពារ ចុះ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៩៣

### សំរេច

ប្រការ ១ : បង្កើតគណៈកម្មការពិគ្រោះការងារ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការ រវាងរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងដើម្បីរៀបចំកងកំលាំងប្រដាប់អាវុធកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ÷

១. ឯកឧត្តម ឧត្តមសេនីយ៍ សក់ សុតសាខន ទីប្រឹក្សាអមសហប្រធាន នៃរដ្ឋាភិបាលបណ្តោះអាសន្ននៃកម្ពុជាទទួលបន្ទុកកិច្ចការការពារជាតិ ជាប្រធាន

២. ឯកឧត្តម ឧត្តមសេនីយ៍ឯក ទៀ បាញ់ អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធាន

៣. ឯកឧត្តម ឧត្តមសេនីយ៍ឯក ទា ចំរ៉ាត់ អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធាន

៤. ឯកឧត្តម ឧត្តមសេនីយ៍ឯក កែ គីមយ៉ាន នាយអគ្គសេនាធិការនៃ កងទ័ពជាតិ ជាអនុប្រធាន

៥. ឯកឧត្តម ស៊ុំ ម៉ានិត អនុរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៦. ឯកឧត្តម អ៊ុច គីមអន អនុរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៧- ឯកឧត្តម ឡាយ ព្រហស្ស អនុរដ្ឋមន្ត្រីក្រសួងផែនការ ជាសមាជិក

៨- ឯកឧត្តម ខិត មុន្នី អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ ជាសមាជិក

៩- ឯកឧត្តម ឧត្តមសេនីយ៍ឯក ទន់ ចាយ អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ជាសមាជិក

១០- ឯកឧត្តម ចម ប្រសិទ្ធ អនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ជាសមាជិក

១១- ឯកឧត្តម គាន់ ម៉ន អនុរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនិងការងារ ជាសមាជិក

១២- ឯកឧត្តម ឆាយ ថន អនុរដ្ឋមន្ត្រីក្រសួងអតីតយុទ្ធជន ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះ ស្ថិតក្រោមការដឹកនាំដោយផ្ទាល់របស់សហប្រធាន នៃ រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា និង ជាសហអគ្គមេបញ្ជាការ នៃកងកំលាំងប្រដាប់អាវុធជាតិកម្ពុជា មានភារកិច្ចធ្វើការពិគ្រោះគ្នាដោយទៀងទាត់នៅក្នុងក្របខណ្ឌ នៃគណៈកម្មការរួមមួយ រវាងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា និង រដ្ឋាភិបាល នៃសាធារណរដ្ឋបារាំង ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការ រៀបចំកងកំលាំងប្រដាប់អាវុធកម្ពុជា តាមកិច្ចព្រមព្រៀង នៃភាគីទាំងពីរ និងរៀបចំនូវរាល់គំរោងកិច្ចព្រមព្រៀង និង ការសំរបសំរួលបច្ចេកទេសជាទ្វេភាគីដោយឡែក ៗ និងកំណត់អោយគ្រប់ខ័ណ្ឌ និង ថែបច្ច នៃសកម្មភាពសហប្រតិបត្តិការ ដែលត្រូវអនុវត្តនៅលើ មូលដ្ឋាននៃគោលការណ៍ដែលបានចែងនៅក្នុងកិច្ចព្រមព្រៀង ។

ប្រការ ៣ : ដោយផ្អែកលើការសំរបសំរួលបច្ចេកទេសជាទេភាគីដោយឡែក ៗ គណៈកម្មការនេះមានភារកិច្ចរៀបចំជាអនុគណៈកម្មការតាមទំហំការងារជាក់ស្តែង ដើម្បីធ្វើការងារទៅតាមជំនាញនិមួយ ៗ ។

ប្រការ ៤ : ទីកន្លែងប្រជុំការងារ ក្នុងគណៈកម្មការរួមធ្វើនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងផែនការ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង

សន្តិសុខជាតិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង ការងារ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអតីតយុទ្ធជន និង ឯកឧត្តម អស់លោកដែលមានរាយនាមក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

*****

ភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ ២៣ សសរ

## ស្តីពីការបង្កើតគណៈកម្មការចម្រុះពង្រឹងសន្តិសុខនៅតាម ខេត្ត ក្រុង នានា

* * *

## រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំង រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងសារាចរលេខ ០២ សរ ស្តីពីរបៀបរៀបរយ និង សន្តិសុខសាធារណៈរបស់រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៣
- តាមសំណើរបស់ឯកឧត្តម ឧត្តមសេនីយ ទីប្រឹក្សាអមសហប្រធាន នៃរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជាទទួលបន្ទុកកិច្ចការ ការពារជាតិ